

# សេចក្ដីណែនាំអំពីសំណងគ្រោះថ្នាក់ស្លាប់ និងការឧបត្ថម្ភបុណ្យសព សម្រាប់ពលករបរទេស E-9

*នេះជាសេចក្ដីណែនាំអំពីប្រព័ន្ធនៃដំណើរការធ្វើបុណ្យសព សំណង និងការឧបត្ថម្ភថ្លៃបុណ្យសពដល់ពលករបរទេសដែលបានស្លាប់ពេលធ្វើការនៅកូរ៉េ។*

## 1 រាយការណ៍អំពីគ្រោះថ្នាក់

### ប៉ុស្ដិ៍ប៉ូលិស•មជ្ឈមណ្ឌលការងារ•ស្ថានទូត(ខ្មែរ)នៅកូរ៉េ

- **ថៅកែ**
  រាយការណ៍ទៅកាន់ប៉ុស្ដិ៍ប៉ូលិស (បូករួមទាំង 119) ឬមជ្ឈមណ្ឌលការងារ នៅពេលមានពលករបរទេសស្លាប់
- **ប៉ុស្ដិ៍ប៉ូលិស និងមជ្ឈមណ្ឌលការងារ**
  ឲ្យដំណឹងអំពីការស្លាប់ អំពីការមកដល់នៃគ្រួសារសព ឬដំណើរការរបស់គណៈប្រតិភូ (សមាគមន៍ពលករអន្តោប្រវេសន៍ ជាដើម) មកកាន់ស្ថានទូតនៅកូរ៉េនៃប្រទេសដែលបញ្ជូនមក។

## 2 ការស៊ើបអង្កេតនៅកន្លែងហេតុ

### សេចក្ដីលំអិត និងមូលហេតុនៃគ្រោះថ្នាក់•ការបំភ្លឺពីសាក្សី

- ស្ថាប័នប៉ូលិសឲ្យដំណឹងដល់ថៅកែ និងស្ថានទូតខ្មែរនៅកូរ៉េ(គ្រួសារសព) អំពីលទ្ធផលនៃការស៊ើបអង្កេតគ្រោះថ្នាក់ រីឯមជ្ឈមណ្ឌលការងារ ឲ្យដំណឹងទៅកាន់ស្ថាប័នពាក់ព័ន្ធផ្សេងៗ

| ប្រភេទ | ស្ថាប័នទទួលបន្ទុក | ចំណុចដែលជួយឧបត្ថម្ភ |
|---|---|---|
| គ្រោះថ្នាក់ការងារ | មណ្ឌលសុខុមាលភាពពលករ | ផ្ដល់ប្រាក់ធានារ៉ាប់រងគ្រោះថ្នាក់ការងារ (មធ្យមភាគនៃប្រាក់ខែចំនួន 1300ថ្ងៃ) |
| គ្រោះថ្នាក់ឧប្បទ្ទវហេតុ | សាំសុងហ្វាជេ | ផ្ដល់ប្រាក់សំណងស្លាប់ដោយឧប្បទ្ទវហេតុ (ច្រើនបំផុត 30លានវ៉ុន) |
| គ្រោះថ្នាក់ជំងឺ | សាំសុងហ្វាជេ | ផ្ដល់ប្រាក់សំណងស្លាប់ដោយជំងឺ (ច្រើនបំផុត 15លានវ៉ុន) |
| អត្តឃាត ឬគ្រោះថ្នាក់ស្លាប់របស់ពលករដែលពុំមានក្រុមគ្រួសារសាច់ញាតិ | ស្ថានទូតនៅកូរ៉េនៃប្រទេសដែលបញ្ជូនមក | (ក្រុមហ៊ុនធ្វើបុណ្យសព) រៀបចំធ្វើបុណ្យសព (មជ្ឈមណ្ឌល) វិក្កយបត្រថ្លៃចំណាយបុណ្យសព * បូករួមទាំងឯកសារភស្ដុតាង |
| | មណ្ឌលធនធានមនុស្សកូរ៉េ | ផ្ដល់ប្រាក់ថ្លៃចំណាយតាមវិក្កយបត្រ (ផ្ដល់ប្រាក់ការចំណាយ ក្នុងអំឡុងពេល14ថ្ងៃ សរុបមិនលើសពី3លានវ៉ុន) |

## 3 ដំណើរការធ្វើបុណ្យសព

### ការពិគ្រោះជាមួយគ្រួសារសព•ការរៀបចំដុតសព ធាតុ និងបណ្ដាំ•ការបញ្ជូនធាតុសព ។ល។

- ស្ថានទូត (ឬសមាគមន៍គណៈប្រតិភូ) ទទួលលិខិតស្នើស្ដីអំពី ការដុតសព ឬធ្វើមាតុភូមិនិវត្តន៍សាកសព ពីក្រុមគ្រួសារសព ហើយធ្វើការប្រមូលធាតុសព តាមរយៈក្រុមហ៊ុនធ្វើបុណ្យសពដែលបានកំណត់ក្នុងប ប្រទេសកូរ៉េ ទៅតាមយោបល់របស់ក្រុមគ្រួសារសព។

ករណីក្រុមគ្រួសារជួបទុក្ខលំបាកក្នុងការចំណាយលើការរៀបចំបុណ្យសព
នឹងមានការផ្ដល់ប្រាក់ជំនួយស្ដង់ដារទៅតាមស្ថានទូតនៅកូរ៉េនៃប្រទេសដែលបញ្ជូនមក

| បុណ្យសព | ដុតសព | រៀបចំចាក់ថ្នាំសព | បញ្ជូនធាតុសព | បញ្ជូនឆ្អឹងសព |
|---|---|---|---|---|
| (មិនលើសពី២លានវ៉ុន) | (10ម៉ឺនវ៉ុន~1លានវ៉ុន) | (2.5លានវ៉ុន~5លានវ៉ុន) | (40ម៉ឺនវ៉ុន~1លានវ៉ុន) | (60ម៉ឺនវ៉ុន~1.5លានវ៉ុន) |

## 4 ការផ្ដល់ប្រាក់ធានារ៉ាប់រង និងប្រាក់បៀវត្សរ៍

### បប្រាក់ខែការងារ ・ធានារ៉ាប់រង សម្រាប់ពលករបរទេស

- ប្រាក់ខែការងារធានារ៉ាប់រងនិងប្រាក់ខែផ្សេងៗ ដែលផ្ដល់ដោយស្ថាប័នទទួលបន្ទុក អាស្រ័យលើប្រភេទគ្រោះថ្នាក់ និង ការផ្ដល់ប្រាក់ថ្លៃចំណាយធ្វើមាតុភូមិនិវត្តន៍ • ធានារ៉ាប់រងប្រាក់បំណាច់ឆ្នាំ និងប្រាក់សោធនិវត្តន៍ជាតិ (ប្រសិនបើបានចុះឈ្មោះ)

ការស្នើសុំប្រាក់ធានារ៉ាប់រង៖ ថៅកែ, ស្ថានទូត, គ្រួសារសព (ឬសមាគមន៍គណៈប្រតិភូពីខាងគ្រួសារសព) ។ល។

| ធានារ៉ាប់រងការធ្វើដំណើរ | ធានារ៉ាប់រងថ្លៃចំណាយធ្វើមាតុភូមិនិវត្តន៍ | ធានារ៉ាប់រងប្រាក់បៀវត្សរ៍ | ប្រាក់ខែ | ប្រាក់សោធនិវត្តន៍ជាតិ |
|---|---|---|---|---|
| (រយៈពេល1ឆ្នាំ គិតចាប់ពីថ្ងៃចុះឈ្មោះ) | (ដែនកំណត់ត្រឹម 40~60ម៉ឺនវ៉ុន ទៅតាមប្រទេស)) | (ដែនកំណត់ត្រឹម 2លានវ៉ុន នៅពេលមិនទទួលបានប្រាក់ខែ) | (ប្រាក់ខែទូទាត់ ទៅតាមម៉ោងធ្វើការងារ) | (ប្រសិនបើបានចុះឈ្មោះ) |



# ការឧបត្ថម្ភថ្លៃចំណាយលើបុណ្យសព នៅពេលមានការស្លាប់ដោយអត្តឃាត ឬគ្មានក្រុមគ្រួសារសាច់ញាតិសព

## សេចក្តីសង្ខេប

- ជាប្រព័ន្ធដែលផ្តល់នូវថ្លៃចំណាយចាំបាច់ក្នុងបុណ្យសព មិនលើសពី3លានវ៉ុន សម្រាប់ការរៀបចំធ្វើបុណ្យសពឲ្យពលករដែលស្លាប់ដោយសារធ្វើអត្តឃាត ឬសពគ្មានក្រុមគ្រួសារសាច់ញាតិ ក្នុងអំឡុងពេលធ្វើការនៅកូរ៉េ។

## អ្នកដែលអាចទទួលបានការឧបត្ថម្ភ

- ពលករបរទេស E-9 ដែលស្លាប់ដោយអត្តឃាត ឬសពគ្មានក្រុមគ្រួសារសាច់ញាតិ

## ថ្លៃចំណាយដែលផ្តល់

- មិនលើសពី 3លានវ៉ុន
  * ឧបត្ថម្ភលើថ្លៃធ្វើបុណ្យសព ដែលចំណាយជាក់ស្តែងលើការចាក់ថ្នាំសព ដុតសព និងបញ្ជូនធាតុ មិនលើសពី3លានវ៉ុន

## ការស្នើ និងការផ្តល់ប្រាក់ឧបត្ថម្ភ

- កន្លែងទទួលពាក្យ៖ មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សកូរ៉េ, ការិយាល័យទ្រទ្រង់ការងារ
- ស្ថាប័នស្នើ៖ ស្ថានទូតនៅកូរ៉េនៃប្រទេសដែលបញ្ជូនមក

ក្រោយពីធ្វើបុណ្យសពចប់សព្វគ្រប់
រៀបចំវិក្កយបត្រការចំណាយលើបុណ្យសពទៅកាន់មណ្ឌលអភិវឌ្ឍន៍ធនធានមនុស្ស
ដោយ ភ្ជាប់មកជាមួយ ពាក្យស្នើប្រាក់ឧបត្ថម្ភបុណ្យសព និងឯកសារភស្តុតាង

## ឯកសារត្រូវការ

- ថ្លៃចំណាយលើបុណ្យសព៖ ពាក្យស្នើប្រាក់ឧបត្ថម្ភបុណ្យសព, លិខិតបញ្ជាក់ពីមរណភាព ឬលិខិតវះពិនិត្យសាកសព, វិក្កយបត្រការចំណាយបុណ្យសព, ច្បាប់ចម្លងសៀវភៅធនាគារ (ប្រសិនបើចាយប្រាក់ដោយស្ថានទូត), ច្បាប់ចម្លងសៀវភៅធនាគារ និងវិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនធ្វើបុណ្យសព (ប្រសិនបើចាយប្រាក់ដោយក្រុមហ៊ុនធ្វើបុណ្យសព)
- ការបញ្ជូនធាតុ៖ ពាក្យស្នើប្រាក់ឧបត្ថម្ភបុណ្យសព, ឯកសារភស្តុតាងការបញ្ជូនសព(គម្រោង), លិខិតបញ្ជាក់ការចាក់ថ្នាំសព

## លេខទំនាក់ទំនងស្ថាប័នពាក់ព័ន្ធ

| ឈ្មោះស្ថាប័ន | ខ្លឹមសារទទួលបន្ទុក | លេខទំនាក់ទំនង |
|---|---|---|
| មជ្ឈមណ្ឌលការងារ | បញ្ជាក់គ្រោះថ្នាក់ការងារ | ☎ 1350 |
| មណ្ឌលសុខុមាលភាពពលករ | ផ្តល់ប្រាក់ធានារ៉ាប់រងគ្រោះថ្នាក់ការងារ | ☎ 1588 - 0075 |
| មណ្ឌលប្រាក់សោធននិវត្តន៍ជាតិ | ផ្តល់ប្រាក់សំណងសោធននិវត្តន៍ជាតិសរុប | ☎ 1355 |
| ក្រុមហ៊ុនធានារ៉ាប់រងគ្រោះថ្នាក់ការងារសាំសុង | ផ្តល់ប្រាក់ដំណាច់ឆ្នាំ និងប្រាក់ធានារ៉ាប់រងការចំណាយលើការធ្វើមាតុភូមិនិវត្តន៍ | ☎ 02 - 2261 - 8400 |
| មជ្ឈមណ្ឌលផ្តល់ប្រឹក្សាពលករ | ផ្តល់ការប្រឹក្សា និងបកប្រែច្រើនភាសា ណែនាំអំពីការឧបត្ថម្ភថ្លៃបុណ្យសពសម្រាប់អ្នកស្លាប់ដោយការធ្វើអត្តឃាត | ☎ 1577 - 0071 |



고용노동부 한국산업인력공단 HUMAN RESOURCES DEVELOPMENT SERVICE OF KOREA